ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
១គ១
សាលក្រមរឿងរដ្ឋប្បវេណី
លេខ : ៩១
ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨

សាលដីកា
លេខ : ០៣
ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ០៥ ខែមករា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១ -ឯកឧត្តម ឌិត មុន្ទី ជាប្រធាន
២ -លោក ថែម ស៊ុន ជាចៅក្រម
៣ -លោក វេវៀល មួន ជាចៅក្រមរបាយការណ៍
៤ -លោក ជីវ កេង ជាចៅក្រម
៥ -លោក ស៊ុន នឹម ជាចៅក្រម

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក ថែម សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកា លេខ ៦៦៤ ចុះថ្ងៃទី ០៦.១១.៩៧ នៃសាលក្រមរឿងរដ្ឋប្បវេណីលេខ ៤៩៨ ចុះថ្ងៃទី ១៤.៨.៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ប៉ូ នុំ ភេទប្រុស អាយុ ៥០ឆ្នាំ សញ្ជាតិកម្ពុជា របររកស៊ី មន្ត្រីសាលាខ័ណ្ឌឬស្សីកែវ ទីលំនៅសព្វថ្ងៃ ភូមិផ្សារតូច ឃុំទួលសង្កែ ខ័ណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ។ ឳពុកឈ្មោះ សន ប៉ូ "ស" ម្តាយឈ្មោះ ម៉ៅ នឹម "ស" ។ ដែលមានលោក សុក ថៃ ជាមេធាវី ។

និង ចុងបណ្តឹងសាទុក្ខឈ្មោះ ជា ឈន ភេទប្រុស អាយុ ៦៣ឆ្នាំ សញ្ជាតិកម្ពុជា របររកស៊ី លក់គ្រឿងទេស ទីលំនៅសព្វថ្ងៃ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ស្រុកឬស្សីកែវ ក្រុងភ្នំពេញ ។ ឳពុកឈ្មោះ ថា គី "ស" ម្តាយឈ្មោះ ថា លីមពេង "ស" ។

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារដី និង សុំអោយរុះរើសំណង់ ។

តាមបណ្តឹងសាទុក្ខលេខ ០២ ចុះថ្ងៃទី ០២.០១.៩៨ របស់ឈ្មោះ ប៉ូ នុំ ប្តឹងមិនសុខចិត្តពីសាលដីកា លេខ ៦៦៤ ចុះថ្ងៃទី ០៦.១១.៩៧ របស់សាលាឧទ្ធរណ៍ លើចំនុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលក្រមរឿងរដ្ឋប្បវេណីលេខ ៩១ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ១៩៩៨

របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ០១.៩.៨៥ របស់ឈ្មោះ ជា ឃន ប្ដឹងទាមទារដី និង សុំអោយឈ្មោះ ប៉ូ នុំ រុះរើផ្ទះចេញពីដីរបស់ខ្លួន បាច់ពីពេលនេះដោយអាងហេតុថា នៅ ឆ្នាំ ១៩៨៣ ឈ្មោះ ប៉ូ នុំ បានលង់ផ្ទះរបស់គាត់ រំលោភចូលមកលើដីរបស់ខ្លួនទំហំ ០,៥០មត្រា ១០ម ហើយនៅពេលដែលខ្លួនរៀបចំធ្វើរបង ដើម្បីការពារកុំអោយគាត់រំលោភមកលើទៀត ត្រូវឈ្មោះ ប៉ូ នុំ ជំទាស់ ។

បានឃើញសាលក្រមលេខ ៩៦ "ខ" ចុះថ្ងៃទី ២៥.៧.៨៦ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :

១ -ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ០១.៩.៨៥ របស់ដើមចោទឈ្មោះ ជា ឃន ទុកជាត្រឹមត្រូវតាម ទំរង់ និង គតិច្បាប់ ។

២ -ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ០៥.១២.៨៥ របស់ឈ្មោះ ជា ឃន ផ្ទេរសិទ្ធិអោយឈ្មោះ ងួន ប៉េងគៀ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣ -អោយឈ្មោះ ប៉ូ នុំ រុះរើសំណង់ដែលធ្វើចូលលើដីឈ្មោះ ជា ឃន ទំហំ៣ម៉ែត្រការេ ចេញ បាច់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៤ -បង្គាប់អោយចុងចម្លើយ បង់ប្រាក់ប្រដាប់ក្ដី គឺ ពន្ធចុះបញ្ជីក្ដី ពន្ធហ៊ីង១៨០០៛ រង្វាន់ក្រឡាបញ្ជីការពិចប្រាក់ ២០០៛ រង្វាន់អ្នកប្រឹក្សាដីការកោះ ២០០០៛ រង្វាន់សាក្សី ៣០០០៛ សរុប ៧.០០០៛ ។ ប្រាក់នេះកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់ទុកមុនជាស្រេច កាលបើហួសកំណត់ឧទ្ធរណ៍ បង្គាប់អោយចុងចម្លើយ បង់សងអោយដើមចោទវិញ និងអោយបង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីទំនាស់ ១៥០ដុល្លាអាមេរិក

៥ -សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី សំរេចបើកផ្លូវឧទ្ធរណ៍ រយៈពេលពីរខែតាមច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ០៦.៩.៨៦ របស់ឈ្មោះ ប៉ូ នុំ ប្ដឹងមិនសុខចិត្ត លើសេចក្ដីសំរេច នៃ សាលក្រមទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ២៦៤ ចុះថ្ងៃទី ០៦.១១.៨៧ ដែល មានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :

១ -ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ០៦.៩.៨៦ របស់ចុងចម្លើយឈ្មោះ ប៉ូ នុំ ទុកជា ត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២ -តម្កល់សាលក្រមលេខ ៩៦ "ខ" ចុះថ្ងៃទី ២៥.៧.៨៦ របស់តុលាការក្រុង ភ្នំពេញ ទាំងមូលទុកជាបានការ ។

៣-ទឹកប្រាក់ប្រដាប់ក្តី ដាក់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួច គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និង ចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

៤-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ០២ ចុះថ្ងៃទី ០២.០១.៩៨ របស់ឈ្មោះ ប៉ូ នុំ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណា របស់ឈ្មោះ ប៉ូ នុំ ចុះថ្ងៃទី ០៧.៥.៩៨ ។

បានឃើញសារណាតប របស់ឈ្មោះ ជា យេន ចុះថ្ងៃទី ១៨.៧.៩៨ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូលថា :

-សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង អង្គច្បាប់ហើយ ។ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យពិចារណា ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ប៉ូ នុំ ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះ ឆ្លើយថា :

-នៅចុងឆ្នាំ ១៩៨០ ខ្លួនជាប្រធានភូមិ ផ្ទះខ្លួននិងផ្ទះ ជា យេន នៅជាប់គ្នា មានច្រកចេញចូលជាផ្លូវលំ ពេលគាត់សង់ផ្ទះ គ្មានប្លង់ គ្មានច្បាប់ សង់ចូលផ្លូវលំ ខ្លួនទៅហាមគាត់ គាត់មិនស្តាប់ ខ្លួនមិនសង់ផ្ទះលើដីគាត់ទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ជា យេន ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ ឆ្លើយថា :

-នៅឆ្នាំ ៨៩-៩០ ផ្លូវនេះមិនឯដើរ ។ នៅឆ្នាំ ១៩៩៣ ប៉ូ នុំ គាត់រុះផ្ទះ ហើយសង់បន្ថែមទៀតចូលដីខ្លួន រហូតដល់ជញ្ជាំងផ្ទះខ្លួន ។ ពេលតុលាការវាស់វែង គាត់ថាវាស់ខុស ។

មេធាវីរបស់ចុងចម្លើយធ្វើសេចក្តីសន្និដ្ឋាន ថា :

-ការសាងសង់របស់ឈ្មោះ ជា យេន គឺសង់ខុសប្លង់អនុញ្ញាតិរបស់មន្ទីររៀបចំក្រុង និង សំណង់ ។ ការចុះវាស់វែងរបស់មន្ទីររៀបចំក្រុង និង សំណង់ មិនបានសហការណ៍ជាមួយរដ្ឋអំណាចមូលដ្ឋាន ឬអ្នកមានព្រំប្រទល់ជាប់គ្នា គឺធ្វើឡើង តាមការចង្អុលបង្ហាញរបស់

របស់ឈ្មោះ ជា ឆេន ។

សំណូមពរ សុំបដិសេធសាលក្រម និង សាលដីការបស់សាលាឧទ្ធរណ៍

-រក្សាទុកផ្លូវចេញចូលនៅដដែល

-បដិសេធរាល់លិខិត និង ប្លង់របស់សំណង់ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី និង សេចក្តីសន្និដ្ឋាន របស់មេធាវី ចុងចម្លើយ

-ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់

តុលាការកំពូល

-ដោយឃើញថា បណ្តឹងសាទុក្ខលេខ ០២ ចុះថ្ងៃទី ០២.០១.៩៨ របស់លោក ប៉ូ នុំ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃ ច្បាប់ស្តីពី ការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-ដោយឃើញថា តាមលិខិតលេខ ០០២ របត ចុះថ្ងៃទី ០៤.០១.៩៦ របស់ការិយាល័យភូមិបាលស្រុកឫស្សីកែវ និង លិខិតលេខ ៥០២ បត ចុះថ្ងៃទី ១៤.៦.៩៦ របស់សូរិយោដីរាជធានីភ្នំពេញ លោក ប៉ូ នុំ ពិតជាបានសង់ផ្ទះចូលក្នុងដីរបស់លោក ជា ឆេន ចំនួន ៣ម៉ែត្រការេប្រាកដមែន ដូច្នេះ លោក ប៉ូ នុំ ត្រូវរុះរើសំណង់របស់ខ្លួនចេញពីដីនេះ ដោយខានពុំបាន ។

-ដោយឃើញថា ការដែលលោក ប៉ូ នុំ និង មេធាវីរបស់លោកលើកឡើងថា លោក ជា ឆេន បានសង់ផ្ទះ លើសប្លង់អនុញ្ញាត របស់រដ្ឋអំណាចក្រុងនោះ តុលាការកំពូលពុំមានសមត្ថកិច្ចពិចារណាឡើយ ពីព្រោះនេះជាសមត្ថកិច្ចរបស់អាជ្ញាធរក្រុងភ្នំពេញ ។

-ដោយឃើញថា ថ្វីបើលោក ជា ឆេន សាងសង់ផ្ទះ មុនការអនុញ្ញាតក៏ពិតមែន ក៏ប៉ុន្តែការសាងសង់នេះ ត្រូវបានទទួលស្គាល់ពីអង្គភាពមានសមត្ថកិច្ចរួចហើយ ។

-ដោយឃើញថា សាលដីការដ្ឋប្បវេណីលេខ ៦០៤ ចុះថ្ងៃទី ០៦.១១.៩៧ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ០២ ចុះថ្ងៃទី ០២ ខែមករា ឆ្នាំ ១៩៩៨ របស់លោក ប៉ូ នុំ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

-៤-

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៦៦៤ ចុះថ្ងៃទី ០៦.១១.៨៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងស្រុង ។

៣-ទីបរត្តប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០ រៀល ដែលលោក ប៉ូ នុំ បានបង់រួចហើយ គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹងចំនួន ៥.០០០ រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០ រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីការពិចប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកានោះ ចំនួន ១៤.០០០ រៀល សរុប ១៩.០០០៛ ។

បង្គាប់អោយលោក ប៉ូ នុំ បង់ពន្ធលើមាត្រា តាមការកំណត់របស់តុលាការក្រុងភ្នំពេញ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៥ ខែមករា ឆ្នាំ ១៩៨៩ ។